# ការសម្ភាសរបស់បងស្រី ឈឿន សុណា

កះអ្នកសម្ភាសឈ្មោះគង់ សីហា ខះអ្នកដែលត្រូវបានគេសម្ភាស ឈ្មោះឈឿន សុណា

កះបាទ!បងឥឡូវខ្ញុំសូមថ្លែងអំណរគុណដល់បងដែលបងផ្តល់ឱកាសដើម្បីអោយខ្ញុំមកសម្ភាសបងអញ្ចឹងណាស់បងហើយខ្ញុំដឹងថានេះគឺជាពរជ័យមួយសម្រាប់កូនចៅយើងជំនាន់ក្រោយជាពិសេសដល់មនុស្សដ៏ទៃទៀតដើម្បីបានដឹងពីជីវប្រវត្តិរបស់យើងថាតើយើងឆ្លងកាត់ដោយរបៀបណាតាមការឈឺចាប់ម៉េចស្រណុកសុខសប្បាយ
ម៉េចអញ្ចឹងណាស់បងហើយបានដឹងពីជីវប្រវត្តិពួកខ្មែរយើងយ៉ាងម៉េចដែរ។
ហើយសម្រាប់ខ្ញុំមានឈ្មោះថាគង់
សីហាជាអ្នកសម្ភាសហើយធ្វើឡើងនៅថ្ងៃទី១៣ខែសីហាឆ្នាំ២០១៦
ធ្វើនៅផ្ទះបងស្រីនៅតាខ្មៅ ហើយខ្ញុំចង់សួរ សំនួរថាបងមានឈ្មោះពេញឈ្មោះអីដែរបង?

ខះខ្ញុំឈ្មោះឈឿន សុណាហៅមុំ ហៅស្រីមុំ។

កះស្រីមុំណោះហើយបងមានអាយុប៉ុន្មានបង?

ខះខ្ញុំអាយុ៣៦ឆ្នាំ។

កះ ហើយបងកើតនៅថ្ងៃខែឆ្នាំណាដែលសត្វអីគេដែរ?

ខះ ខ្ញុំកើតនៅភូមិព្រះបាទជាន់ជុំ ស្រុកគីរីវម្យ ខេត្តតាកែវ ឆ្នាំមមែគឺសត្វពពែ។
ហ្នឹងហើយកើតនៅថ្ងៃទី២២ ខែកុម្ភះ ឆ្នាំ១៩៨០។

កះ អ៎!
អរគុណច្រើនហើយអឺអញ្ចឹងបងបានរៀបបងបានឆ្លងកាត់ការរៀបអាពាហ៍ពិពាហ៍ដែរមែនបង
?

ខះ ចា៎! ខ្ញុំធ្លាប់ឆ្លងកាត់រៀបអាពាហ៍ពិពាហ៍ពីមុខម្តងហើយក្រោយនេះម្តងទៀត។

កៈ អ៎! អញ្ចឹងបាទ!
ចុះបងពេលរៀបអាពាហ៍ពិពាហ៍ពីមុខបងអឺពីមុខបងធ្លាប់រៀបអាពាហ៍ពិពាហ៍ពីពេលណាដែរពីមុន?

ខៈ ពីមុខធ្លាប់រៀបអាពាហ៍ពិពាហ៍នៅព្រះវិហារដែរ ហើយអឺតាំងពីឆ្នាំ២០១០។

កៈ ២០១០ណោះ។

ខៈ ថ្ងៃទី១៨ ខែមិនា។

កៈ បាទ!
បងហើយសម្រាប់ហេតុអីបានជាបងរៀបអាពាហ៍ពិពាហ៍លើកទីពីរកើតអីផ្សេងរឺក៏យ៉ាងម៉េចដែរបង?

ខៈ ក្រោយមកខ្ញុំបានដូចជានៅជាមួយគ្នាបានប៉ុន្មានខែដាច់គ្នាបួនប្រាំខែដាច់គ្នា?

កៈអ៎!

ខៈ ទាល់តែប្រាំ
ប្រាំមួយឆ្នាំក្រោយមកបានខ្ញុំជួបម្នាក់មួយផ្សេងទៀតខ្ញុំទើបរៀបការនៅសាខាតាខ្មៅហ្នឹងពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦នេះ។

កៈបាទ! បងអរគុណច្រើនសម្រាប់ទាំងអស់នេះ។
ហើយចង់សូមសួរថាពេលបងរៀបអាពាហ៍ពិពាហ៍នេះធ្វើឡើង
ដោយឪពុកម្តាយជួយដឹងលឺដែរ រឺក៏បងរៀបអាពាហ៍ពិពាហ៍ដោយខ្លួនឯង?

ខៈ ចា៎!
ដោយសារតែពួកខ្ញុំបានបោះសំបុត្រអាពាហ៍ពិពាហ៍ហើយបានខាងប្រុសជំរាបទៅប៊ីស្សពក៏ដូចជា សមា
ជិកគាត់រៀនការនៅស្រុកខ្មែរនេះដោយសារប្តីខ្ញុំជាជនជាតិអាមេរិចកាំងហើយជាអែលឌើរត្រលប់ពីបេសកម្ម ហើយខ្ញុំជាស៊ីស្ទើរត្រលប់បេសកម្មនៅស្រុកខ្មែរនេះ។

ក៖ បាទ!

ខ៖ អញ្ចឹងពួកយើងបានមករៀបការនៅស្រុកខ្មែរនេះតែម្តង។
ហើយមានឪពុកម្តាយដឹងលឺទាំងអស់។

ក៖ អ៎! មានឪពុកម្តាយដឹងលឺ។

ខ៖ ចា៎ៗ!

ក៖ ហើយពេលបងការហ្នឹងខាងប្រុសអោយបណ្ណាការជូនបងខ្លះទេ?

ខ៖ អឺ! កាលហ្នឹងតាមធម្មតាប្រពៃណីខ្មែរត្រូវតែមានបណ្ណាការហើយ។

ក៖ ហ្នឹងហើយបងប៉ុន្មាន?

ខ៖
ខ្ញុំគិតថាគេមកអស់ច្រើនថ្លៃជំនួនផងហើយណាមួយខ្ញុំការហើយម្តងខ្ញុំអត់ចង់ធ្វើអីច្រើនទៀតទេ។

ក៖ ហ្នឹងហើយ។

ខ៖ ចា៎! ដល់ពេលហ្នឹងខ្ញុំក៏អត់ទារអីដែរ
គ្រាន់តែថារៀបការអស់ប៉ុន្មានលើខាងប្រុសទាំងអស់។

ក៖ អ៎!

ខ៖ ហ្នឹងហើយ។

ក៖ បងការហ្នឹងចំនេញក៏ខាត?

ខ៖
ការធម្មតាការនៅស្រុកខ្មែរអត់ចំនេញទេលុយហ្នឹងគឺជាលុយបោះចោលលុយរៀបការគឺលុយបោះចោលគ្រាន់ តែយើងចង់មានកម្មវិធីមួយតាមប្រពៃណីខ្មែរអោយចាស់ទុំដឹងលឺ។

កៈ បាទ! បងហ្នឹងហើយ។

ខៈ ចាំ!

កៈ
ហើយខ្ញុំចង់សុំសួរសំនួរបងបន្ថែមទៀតអំពីការជួបគ្នាព្រោះអីម្នាក់នៅឯងក្រៅប្រទេសម្នាក់នៅស្រុកខ្មែរអញ្ចឹង ណាំថា តើហេតុអីជួបគ្នាតាមរបៀបណាវិញ?

ខៈអីដែលបទពិសោធដែលមិនអាចបំភ្លេចបាននោះគឺខ្ញុំមានព្រះវិញ្ញាណមកហើយខ្ញុំជឿថាខ្ញុំដឹងប្រាដកថាព្រះជាអ្នករៀបចំដោយសារតែខ្ញុំមិនដែលស្គាល់គ្នាសោះខ្ញុំមិនដឹងថាគាត់ជានរណាហើយនៅកន្លែងណា។

កៈ បាទ!

ខៈ
ហើយគ្រាន់តែដឹងលឺថាប្រព័ន្ធព្រះវិហារយើងគឺមានឈ្មោះថាប្រព័ន្ធស្វែងរកដៃគូនោះគឺមានឈ្មោះថាwww.ldsplanet.com.

កៈ បាទ!បង។

ខៈ
ហើយខ្ញុំអត់ដឹងអីច្រើនទេគ្រាន់តែលឺតាមគេហើយមានស៊ីស្ទើរម្នាក់នៅអាមេរិចកាំងឈ្មោះឡាសិនគាត់បាន
ចូលប្រព័ន្ធហ្នឹងអោយដំបូងឡើងខ្ញុំប្រកែកដាច់ខាតខ្ញុំអត់ធ្វើដោយសារតែអស់សូវចេះអង់គ្លេសប៉ុន្តែនៅពេលដែលព្រះវិញ្ញាណមកព្រះវិញ្ញាណចូលសណ្ឋិតនៅក្នុងខ្លួនខ្ញុំហ្នឹងណាពេលរសៀលចូលប្រាប់ថាពេលមកដល់ចូលសណ្ឋិតមកខ្លួនខ្ញុំ
ខ្ញុំបានគាំងមួយសន្ទុះហើយក៏បានប្រាប់ខ្ញុំថាបើអ្នកឯងអត់ប្រើប្រព័ន្ធហ្នឹងទេ ព្រះវរបិតាអត់ដឹងប្រទានពរអ្នកតាមរយៈអ្វីទេអញ្ចឹងទាល់តែអ្នកឯងប្រើប្រព័ន្ធមួយហ្នឹងគ្រាន់តែនិយាយចប់ប៉ុណ្ណឹងខ្ញុំគាំងមួយសន្ទុះហើយខ្ញុំក៏ចាប់ផ្តើមដឹងខ្លួនវិញខ្ញុំភ្ញាក់ខ្លួនអញ្ចឹងទៅ។

កៈ បាទ!

ខ៖ ក៏ខ្ញុំចាប់ផ្ដើមធ្វើវាដើររកគេរកឯងអោយជួយរកប្រព័ន្ធហ្នឹង។ អញ្ចឹងស៊ីស្ទើរ ឡា
សិនគាត់បានចូលប្រព័ន្ធហ្នឹង ldsហ្នឹងអោយខ្ញុំ។
ខ្ញុំចូលបានតែបីថ្ងៃមុខដំបូងខ្ញុំលុតជង្គង់អធិស្ឋានសិនមុខហ្នឹងប្រើប្រព័ន្ធហ្នឹង។

ក៖ ហ្នឹងហើយ។

ខ៖
ខ្ញុំបានលុតជង្គង់អធិស្ឋានសូមព្រះអង្គជួយនាំបុរសម្នាក់អោយរៀបការជាមួយខ្ញុំដែលនៅក្នុង
សាសនាចក្រ
នេះបានអោយខ្ញុំចូលព្រះវិហារបានផ្សារភ្ជាប់អញ្ចឹងសូមព្រះអង្គនាំបុរសអាមេរិចកាំងម្នាក់មុន
ហ្នឹងប្រើប្រព័ន្ធហ្នឹងខ្ញុំអធិស្ឋានចាំៗអញ្ចឹងហើយចេះតែlikeគេ៦០នាក់ទៅ។

ក៖ ហ្នឹងហើយ។

ខ៖
ក្រោយពីអធិស្ឋានហើយក៏បានចូលទៅបានបីថ្ងៃក្រោយមកក៏បានមានបុរសម្នាក់និយាយជាមួ
យខ្ញុំ៥០នាក់ ទៀតគេអត់និយាយជាមួយខ្ញុំសោះ។

ក៖ ហ្នឹងហើយ។

ខ៖
ខ្ញុំមានអារម្មណ៍ថាចំលែកខ្លាំងដោយសារអីដោយសារមនុស្សច្រើនណាស់ដែលlikeហេតុអីអត់
មានអ្នក
និយាយជាមួយខ្ញុំសោះមានតែម្នាក់អញ្ចឹងហើយខ្ញុំមានអារម្មណ៍ដឹងថាព្រះអង្គរៀបចាំអោយខ្ញុំ
មិនបង្វែងដានមិនអោយបុរសបួន ប្រាំនាក់មកឆាថៅខ្ញុំសោះគឺមានតែម្នាក់ហ្នឹងគត់
ហើយម្នាក់នោះគាត់ជាអ្នកត្រលប់ពីបេសសកម្ម
នៅស្វីដែនដែលគាត់រស់នៅអាលីសូណាសព្វថ្ងៃហើយគាត់បានទាក់ទងខ្ញុំមានតែគាត់មួយនិ
យាយរកខ្ញុំរាល់ថ្ងៃហើយយើងមានskyeជាមួយគ្នា។
skyeដំបូងឡើយយើងចាប់ផ្ដើមអធិស្ឋានមុនហ្នឹងនិយាយអធិស្ឋានម្នាក់ម្ដង
ហើយខ្ញុំក៏បានចាប់ផ្ដើមនិយាយគ្នាចែកចាយព្រះគម្ពីរជាមួយគ្នាហើយក៏និយាយអំពីព្រះជាមួ

យគ្នាទៅហើយក៏
មានអារម្មណ៍មាននិស្ស័យជាមួយគ្នាអញ្ចឹងធ្វើអោយខ្ញុំចាប់ផ្តើមតមអាហារខ្ញុំតមអាហារបាន
ប្រាំដងដើម្បីសូមពរ
ជ័យពិតប្រាដកដល់អញ្ចឹងគាត់មករៀបការមែនគាត់មករៀបការមែនខ្ញុំតមអាហារបានប្រាំដង
អញ្ចឹងឃើញថាដៃគូខ្ញុំឃើញថាគាត់ហើយនិងខ្ញុំគឺរៀបចំឡើងដោយព្រះអង្គម្ចាស់ដែលខ្ញុំដឹង
យ៉ាងពិតប្រាកដគឺមានព្រះវិញ្ញាណដឹងនាំផ្លូវ។

ក៖ បាទ!
បងហ្នឹងហើយអរគុណច្រើនសម្រាប់បងប្រាប់ពីរឿងរ៉ាវរបស់បងអញ្ចឹងណាស់ណាខ្ញុំមានអារម្ម
ណ៍
sweetម៉ងណាស់ហ្នឹងហើយដល់ពេលអញ្ចឹងបងរាល់ថ្ងៃបងមានបងប្អូនប៉ុន្មាននាក់ដែរបង?

ខ៖អឺខ្ញុំមានបងប្អូន៩នាក់។ស្រី៤ប្រុស៥។

ក៖បងអាចរៀបរាប់ឈ្មោះពួកគាត់និងអាយុពួកគាត់ផងបានទេបង?

ខ៖ចាំ! បងប្រុសបង្អស់គាត់មានឈ្មោះឈឿន ឈន អាយុ៣៨ឆ្នាំ។

ក៖បាទ!

ខ៖ហើយបងប្រុសបន្ទាប់គឺគាត់ឈ្មោះឈឿនសុវណ្ណដារ៉ា អាយុ៣៧ឆ្នាំ។ ហើយខ្ញុំឈឿន
សូណា អាយុ៣៦ឆ្នាំ។ បន្ទាប់មកប្អូនស្រីអាយុ៣៤ឆ្នាំ ឈ្មោះឈឿន សេថា
ហើយបន្ទាប់មកឈ្មោះឈឿន សុគន្ធា អាយុ៣១ឆ្នាំ បន្ទាប់ មកឈឿនគន្ធី
ឆ្នាំថ្មីហ្នឹងគាត់ចូលអាយុ៣០ហើយ ហើយបន្ទាប់មកឈឿន ដារុធអាយុ២៨ឆ្នាំ
បន្ទាប់មកឈឿន ច័ន្ទមន្នីរ: ដែលគាត់បំរើបេសកម្មនៅប្រទេសអូស្ត្រាលី
អញ្ចឹងគាត់អាយុ២៦ឆ្នាំ ហើយបន្ទាប់មកប្អូនស្រីពៅទេព មន្នីរ័ត្ន
ការពិតត្រកូលឪពុកឈ្មោះឈឿន មន្នីរ័ត្ន។ ចាំ! ហើយម្តាយបានដាក់ឈ្មោះត្រកូលទេព
ដោយសារ ត្រកូលតាគាត់ គាត់ស្រលាញ់ឪគាត់ខ្លាំងដាក់ត្រកូលទេព
មន្នីរ័ត្នដល់ពេលអញ្ចឹងគាត់អាយុទើបតែ២០ឆ្នាំទេ។

ក៖ បាទ! ចុះរាល់ថ្ងៃគាត់នៅជាមួយបងរឺក៏មានអ្នកខ្លះបែកហើយ។

ខ៖ អឺ!
បែកគ្នាខ្លះហើយដោយសារតែគេរៀបការអស់ខ្លះបងប្រុសពីរនាក់ចេញទៅនៅផ្ទះផ្សេងចំនែក
ខ្ញុំរៀបការ ហើយខ្ញុំអត់ទាន់បានចេញទេ។
ខ្ញុំនៅជុំគ្នាតិចទៀតគ្រួសារខ្ញុំមកខ្ញុំនឹងទៅនៅជាមួយគ្រួសារខ្ញុំ។ ចាំ!

ក៖ បាទ! អរគុណច្រើន។
ហើយអញ្ចឹងអឺខ្ញុំចង់សួរអំពីឪពុកម្ដាយរបស់បងវិញបងឪពុកម្ដាយបងមានឈ្មោះអីគេ ខ្លះដែរ?

ខ៖ ឪពុកខ្ញុំឈ្មោះកែម ឈឿន អាយុ៦៨។ ម្ដាយឈ្មោះទេព សារឿន អាយុ៦០ឆ្នាំ។

ក៖ ៦០ឆ្នាំបងណោះហើយគាត់ប្រកបការងារអីដែរឥឡូវ?

ខ៖ ឪពុកខ្ញុំគឺជាជាងដែកនៅក្រុមហ៊ុនមួយហើយម្ដាយខ្ញុំនៅផ្ទះមើលកូនចៅ។

ក៖ អ៎! ហើយបងបានដឹងអ្វីខ្លះអំពីជីវប្រវត្តិរបស់ពួកគាត់?

ខ៖ពួកគាត់ចិញ្ចឹមកូនវេទនាដោយសារកូន៩នាក់អត់មានបាយទឹកហូបទេពួកយើងវេទនាផ្សង
ព្រេងជាមួយគ្នា រហូតដល់ជួបព្រះ
ហើយឪពុកខ្ញុំទៅធ្វើការតាមខេត្តហើយម្ដាយខ្ញុំគាត់ភាពច្រើនឆ្លងទន្លេម្នាក់ឯង។

ក៖បាទ! បងហ្នឹងហើយ។

ខ៖វេទនាដែលចិញ្ចឹមកូនតូចៗមកលំបាក៩នាក់ហ្នឹងហើយអត់អាចបែកគ្នាបានគាត់នៅតស៊ូចិ
ញ្ចឹមតូចរហូតដល់សព្វថ្ងៃបានជឿព្រះបានស្គាល់ព្រះអញ្ចឹងឃើញថាពួកខ្ញុំអត់មានឪពុកនៅ
ណែនាំច្រើនទេតែបានស្គាល់ព្រះអញ្ចឹងទៅបានព្រះជួយដឹកនាំពួកយើងដើរផ្លូវត្រូវទាំង៩នាក់
អត់មានអ្នកណាមួយដើរផ្លូវខុសឆ្គងតាមសង្គមទាក់ទាញ ទេ។

ក៖ បាទ បង!

ខ៖
គឺយើងមានព្រះពួកយើងនៅតែទៅព្រះវិហារដំណឹងល្អមានក្រឹត្យវិន័យជួយដល់ពួកខ្ញុំដើម្បីធ្វើ
អ្វីត្រឹមត្រូវហើយ ពួកខ្ញុំបានជឿព្រះខ្លាំងមែនទែនមួយគ្រួសារខ្ញុំជឿព្រះខ្លាំងណាស់។

ក៖ ហើយដល់ពេលអញ្ចឹងអីបងចាំអំពីជីដូចជីតារបស់បងទេ។

ខ៖ អ៎!
ខ្ញុំបានចាំតិចតួចដោយសារខ្ញុំនៅតូចពេកខ្ញុំគ្រាន់តែដឹងថាតាមួយគាត់ស្លាប់បាត់តាំងពីខ្ញុំនៅតូចខ្លាំងហើយយាយខ្ញុំគាត់ទើបតែស្លាប់ប្រហែល២០ឆ្នាំនេះទេ។

ក៖ បងចាំឈ្មោះពួកគាត់ទេ។

ខ៖ ចាំតាគាត់ឈ្មោះមុំ ទេព ហើយយីឈ្មោះយឹម អ៊ី។
យាយគាត់ទើបតែស្លាប់ខ្ញុំធំដែលហើយ១៧ឆ្នាំគាត់ស្លប់។

ក៖ អ៎!

ខ៖ ចា៎!
យីខ្ញុំគាត់ជិតហ្នឹងគាត់មើលកូនមើលចៅខាងគាត់ខាងណោះតែគាត់មកអឿតខាងខ្ញុំយូរម្តងៗ
។

ក៖ អ៎!ចុះបងចងចាំភាពលំបាកពួកគាត់អីគេខ្លះ។

ខ៖ តាយាយខ្ញុំ ខ្ញុំអត់សូវដឹងច្រើនគ្រាន់តែតាគាត់ស្លាប់លឿនពេ។
កយាយខ្ញុំដឹងថាគាត់ពិបាកក្នុងការមើលចៅ ខ្លះៗដែរ។

ក៖ ចុះឪពុកម្តាយបងវិញធ្លប់ឆ្លងកាត់រៀនភាសាអីផ្សេងទេបង?

ខ៖ឪពុកម្តាយខ្ញុំអត់ដែលរៀនភាសាអីផង។

ក៖ ហើយពួកគាត់ធ្លប់អញ្ជើញទៅប្រទេសណាផ្សេងក្រៅពីស្រុកខ្មែរទេ?

ខ៖ អ៎! គាត់ធ្លាប់ទៅផ្សារភ្នាប់នៅហុងកុងផ្សារភ្នាប់នៅព្រះវិហារបរិសុទ្ធតែប៉ុណ្ណឹងទេ។

ក៖ កាលបងអញ្ជើញទៅហុងកុងជាមួយគ្រួសារហ្នឹងបងដើរលេងនៅកន្លែងណាខ្លះ?
ហើយមានអនុស្សាវរីយ៍នៅ ហ្នឹងទេបង?

ខ៖
គ្រាន់តែទៅផ្សារទំនើបមួយនៅលើភ្នំកប់ពកកហើយដើរមាត់ទឹកនៅហុងកុងហ្នឹងហើយពួកយើងបានត្រលប់ មកវិញតែប៉ុណ្ណឹង។

ក៖
ហើយអឺខ្ញុំចង់សូមសួរអំពីជីវប្រវត្តិរបស់បងតាំងពីតូចរហូតដល់ធំអ្ហ៎ះបងធ្លាប់ឆ្លងកាត់អ្វីខ្លះតាំងពីបងធំដឹងក្តី?

ខ៖ ឆ្លងកាត់ច្រើនដោយសារខ្ញុំកូនស្រីបងគេខ្ញុំមានបងប្រុសពីរនាក់ហើយខ្ញុំស្រីបងគេណាស់។ ហើយខ្ញុំក្រលំបាក
ខ្លាំងណាស់ក្នុងគ្រួសារហ្នឹងហើយពួកយើងបានសន្យាគ្នាថាពេលញ៉ាំបាយថ្ងៃត្រង់ខ្ញុំបាននិយាយថាពេលឥឡូវ
យើងអត់ខ្លាំងមែនទែនពេលយើងមានយើងកុំភ្លេចគ្នាហ្នឹងអ្វីដែលខ្ញុំនិយាយតាំងពី៣០ឆ្នាំមុខតាំងពីខ្ញុំនៅតូចៗ។ ចា៎!
ពួកខ្ញុំរង់ទុក្ខវេទនាជាមួយម៉ែឪហ្នឹងតស៊ូជាមួយគ្នារហូតសព្វថ្ងៃពួកយើងស្គាល់ព្រះក៏បានចិញ្ចឹមពួកយើង អោយរកស៊ីចេះតែធូរបន្តិចម្តងៗ។

ក៖ អញ្ចឹងខ្ញុំសួរអឺបងឆ្លងកាត់ការរៀនពីមុខមកទេ?

ខ៖ ហ្នឹងហើយខ្ញុំបានរៀនត្រឹមថ្នាក់ទី៨។ ចា៎!
ដោយសារម៉ែឪអត់មានលុយអោយកូនរៀនទេទាំងអស់គ្នាហ្នឹង
ហើយបានឆ្លៀតរៀនភាសាបានពីរឆ្នាំកាលហ្នឹង។
កាលឆ្នាំ១៩៩៧ខ្ញុំបានធ្វើការរោងចក្របណ្តើរខ្ញុំបានរៀន អង់ គ្លេសមួយម៉ោងៗ
ហើយរៀនបានពីរឆ្នាំបានចេះអង់គ្លេសតិចតួច។

ក៖ បាទ! បងហ្នឹងហើយ។
ហើយអញ្ចឹងពេលបងទៅរៀនហ្នឹងបងរៀននៅសាលាណាដែលបងអាចជួយប្រាប់
អាស័យដ្ឋាន និងឈ្មោះបានទេបង?

ខ៖សាលាភូមិបីចាក់អង្រែក្រោមលាសាបឋមពេលខ្ញុំទៅរៀនអង់គ្លេសនៅសាលាហ្នឹងដែលរៀនគួរហើយដល់
ពេលរៀននៅអនុវិទ្យាល័យថ្នាក់ទី៨ហ្នឹងខ្ញុំរៀននៅអនុវិទ្យាល័យនៅចាក់អង្រែក្រោមនៅខាងជើងទៀត។

ក៖បាទ! ហើយដល់ពេលអញ្ចឹងសម្រាប់បងវិញបងរៀនភាសាបានតិចតួច
ចុះបើសិនគ្រួសារបងជនបរទេស អញ្ចឹងចុះការទំនាក់ទំនងជាមួយគ្នា?

ខ៖សម្រាប់ការទំនាក់ទំនងខ្ញុំអាចនិយាយបានគ្រាន់ថាពាក្យជ្រៅជាផ្លូវការខ្ញុំអត់ចេះទេតែត្រឹមនិយាយពីអារម្មណ៍ផ្ទាល់ខ្លួនអំពីការទាក់ទងគ្នាស្នេហាគឺជាជំនាញរបស់របស់ខ្ញុំហើយ។

ក៖ បាទ! អរគុណច្រើន។ បាទ!
ហើយសម្រាប់បងធ្លាប់អញ្ចឹងទៅប្រទេសផ្សេងក្រៅពីប្រទេសខ្មែរអត់បង?

ខ៖ធ្លាប់ទៅប្រទេសហុងកុងពីរដងទៅផ្សារភ្ជាប់ហើយទៅធ្វើស៊ីស្មើរម្តងហើយទៅលេងប្រទេសថៃម្តងតែប៉ុណ្ណឹងទេ។

ក៖ ហើយអញ្ចឹងសម្រាប់បងដែលធ្វើស្រែចម្ការអីទេ?

ខ៖ អត់ដែលផង តែទៅបេសកម្មគេអោយទៅស្ទួងខ្ញុំទៅរៀនស្ទួងខេត្តកំពង់ចាម។

ក៖បាទ! អញ្ចឹងអីនៅក្នុងក្រុមគ្រួសាររបស់បងគាត់ដែលធ្លាប់ធ្វើការរកស៊ីអីផ្សេងៗ?
បងដែលធ្លាប់រកស៊ីពីមុខ មកទេបង?

ខ៖ខ្ញុំធ្លាប់តែធ្វើការរោងចក្រហ្នឹងខ្ញុំអត់ដែលធ្វើអីទៀតផង។ ខ្ញុំធ្លាប់ធ្វើការរោងចក្រ
ធ្វើការអង្គការ ធ្វើគ្រូ ធ្លាប់ធ្វើតែប៉ុណ្ណឹងទេរឿងរកស៊ីអត់ចេះអត់ដែលផង។

ក៖ ហ្នឹងហើយ។ ចុះបងគិតថាជីវិតសព្វថ្ងៃហ្នឹងវាខុសគ្នាម៉េចខ្លះកាលពីក្មេងអញ្ចឹងណាស់បង?

ខ៖ចាំ!
ខុសគ្នាជីវិតដែលខុសគ្នានោះពីក្មេងមកដល់ឥឡូវខុសគ្នាត្រង់ថាពីក្មេងយើងលំបាកផ្ទះលិចទឹកហើយ

យើងអត់មានអីហូបយើងអត់បានស្គាល់ព្រះយើងអត់ដឹងត្រូវធ្វើអីជីវិតទាល់ច្រកដល់ដឹងថាធ្វើអីទេជីវិតទ័លច្រក
ខ្លាំងនៅពេលដែលបច្ចុប្បន្នមកដល់ពេលនេះ១០ឆ្នាំគឺតាំងពីស្គាល់ព្រះមកថាព្រះអោយជីវិតថ្មីមួយទៀតថាយើងមានគោលដៅរបស់យើង។
យើងមានផ្លូវដើរតទៅទៀតមិនមែនផ្លូវទាល់ច្រកទេ។

កៈ ហ្នឹងហើយ។

ខៈ ចាំ! ហើយព្រះអង្គបានដឹកនាំក្រុមគ្រួសារខ្ញុំក៏ដូចជារូបខ្ញុំមិនអោយទាល់ច្រក។ ចាំ! សម្រាប់ជីវភាពពីមុនអត់
ឃ្លានគ្មានអីស៊ីសោះនោះឥឡូវវាមិនទាន់មានតែវាសមរម្យជាងមុខហើយយើងមានពេលខ្លះអាចញ៉ាំឆ្ងាញ់ជាង មុខ។ ចាំ!
តែយើងនៅបន្តជឿព្រះព្រោះអីយើងត្រូវការពរជ័យបន្តទៀតព្រោះអីយើងចង់ដល់ជីវិតមួយដែលយើង
ចង់បានដែលគោលបំណងប្រាថ្នាគឺចង់បានធូរស្រោលជីវភាពធូរខ្លាំងជាងហ្នឹងមែនទែនដែលចង់បាន។

កៈ បាទ! បង។

ខៈ អញ្ចឹងមានតែការអធិស្ឋានទេទើបអ្វីដែលខ្ញុំប៉ងប្រាថ្នាអ្វីដែលខ្ញុំពិភាក្សារាល់ថ្ងៃគឺព្រះមានតែព្រះទេដែលអាច ជួយអោយខ្ញុំបានសមតាមបំណងរបស់ខ្ញុំ។

កៈ ហ្នឹងហើយបង។

ខៈ ចាំ!

កៈ
ហើយសម្រាប់បងថាពីក្មេងបងអត់សូវមានអីញ៉ាំអត់សូមមានម្ហូបឆ្ងាញ់អញ្ចឹងនៅថ្ងៃអនាគតបងមានម្ហូបច្រើន បងចង់ហូបម្ហូបអីគេជាងគេ?

ខៈ ម្ហូបដែលចូលចិត្តជាងគេហ្អេ?

កៈ ហ្នឹង។

ខៈ សាច់គោអាំងប្រឡាក់ហើយនិងបន្លែឆាប៉ុណ្ណឹងទេ។

កៈ បាទ! បង។

ខៈ ហើយហ្នឹងចូលចិត្តអាហារសមុទ្រប៉ុណ្ណឹង។

កៈ ហើយចុះពេលសម្រាប់បងទំនេរបងចូលចិត្តអ្វីអីគេ?

ខៈ
ទំនេរភាគច្រើនខ្ញុំចូលចិត្តច្រៀងលេងជូនកាលខ្ញុំស្តាប់បទព្រះហើយលេងfacebookហ្នឹងដោយសារអត់ទាន់
មានគ្រួសារមកអញ្ចឹងខ្ញុំអផ្សុកខ្ញុំអត់មានធ្វើការអីខ្ញុំចូលចិត្តលេងfacebookតែដល់ពេលមានគ្រួសារមកខ្ញុំបំរើរក្រុមគ្រួសារខ្ញុំអញ្ចឹងខ្ញុំអត់មានពេលលេងfacebookទេ។

កៈ ហ្នឹងហើយសម្រាប់បងវិញបងចេះធ្វើម្ហូបជំនាញទេ?

ខៈ គួរសម្បដែលដោយសារខ្ញុំចូលចិត្តធ្វើម្ហូបផ្សេងៗប្លែកៗ។

កៈ ហើយម្ហូបដែលបងចូលចិត្តធ្វើជាងគេម្ហូបគេ?

ខៈ សម្លម្ជូរត្រីហើយហ្នឹងសាច់អាំងខ្ចប់អាលុយមីញ៉ូមអាំងខ្ញុំចូលចិត្តតែអញ្ចឹង។

កៈ ហើយចុះជាប្រទេសស្រុកខ្មែរបងចូលចិត្តទៅកន្លែងណាជាងគេ?

ខៈ ស្រុកខ្មែរហ្អេ?

កៈ ហ្នឹងហើយ។

ខៈ ខ្ញុំអឺចូលចិត្តទៅកែប។

កៈ ទៅកែប។

ខ៖
និងមានបំណងចង់ទៅលេងជ្រោះសុភ័ក្រមិត្តតែមិនទាន់បានទៅសោះហើយចង់ទៅបឹងយក្សឡោមមិនទាន់ បានទៅវាឆ្ងាយពេក។

ក៖ ហ្នឹងហើយ។

ខ៖ ហ្នឹងហើយ។

ក៖ បាទ! ហើយសម្រាប់បង បងចូលចិត្តលេខgameអីខ្លះដែរ?

ខ៖ gameដែលខ្ញុំចូលចិត្តលេងលោតកៅស៊ូ លោតអន្ទាក់។

ក៖ បាទ!
បងហើយដល់ពេលអញ្ចឹងពេលដែលបងនៅក្មេងរហូតដល់ធំបងដែលមានក្តីស្រម៉ៃអីមួយអត់បង?

ខ៖
ចំនុចហ្នឹងវាចំហ្នឹងអ្វីដែលការពិតកំពុងកើតឡើងកាលពីខ្ញុំអាយុប្រហែលជា៨ឆ្នាំខ្ញុំនៅតូចមែនមែន៨ឆ្នាំហ្នឹង។
ខ្ញុំស្រម៉ៃថាខ្ញុំហ្នឹងចង់ទៅប្រទេសក្រៅមែនខ្ញុំអង្គុយៗចង់ស្គាលប្រទេសគេដល់ហើយមិនដឹងធ្វើយ៉ាងម៉េចទេណោះហើយពួកជនជាតិវាម៉េចទៅរូបរាងម៉េចទៅហើយខ្ញុំគោលបំណងថាខ្ញុំចង់ស្គាល់ប្រទេសគេណាស់ប៉ុន្តែកាលនោះអាយុទាបតែ៨ឆ្នាំទេ។
ប៉ុន្តែឥឡូវនេះអាយុ៣៦ឆ្នាំនេះខ្ញុំចិត្តបានដូចចិត្តដោយសារតែខ្ញុំកំពុងរៀបចាំឯកសារនៅរស់នៅសហរដ្ឋអាមេរិចហើយគ្រួសារខ្ញុំគាត់ធានាខ្ញុំទៅតែខ្ញុំទើបបានពាក់កណ្តាលទីហ្នឹងអធិស្ថានបន្តទៀតដើម្បីអោយឯកសាររត់លឿនហើយដើម្បីអាចទៅនៅជុំក្រុមគ្រួសារហើយយើងអាចស្គាល់ព្រះយើងចង់អានព្រះគម្ពីរជាមួយគ្នាទោះបីជាមិនមានពេកអោយតែគេអោយបាយហូបអោយអាវពាក់គឺវាគ្រប់គ្រាន់សម្រាប់ខ្ញុំហើយ។

ក៖ ហ្នឹងហើយបង។ បងមានអីទៀតទេ។

ខ៖
ហើយខ្ញុំចង់ថ្លែអំណរអគុណអំពីព្រះខ្លាំងមែនទែនដែលខ្ញុំមិនអាចបំភ្លេចបានដោយសារតែព្រះអង្គបានជួយ
ដឹកនាំជីវិតខ្ញុំក៏ដូចជាសូម្បីតែខ្ញុំធ្លាក់នរកទៅហើយក៏ព្រះនៅតែលើកខ្ញុំមកវិញទៀត។

ក៖ ហ្នឹងហើយបង។

ខ៖
ហើយរឿងមិនគួរអោយជឿខ្ញុំចុះនរកជម្រៅណាណាក៏រាប់សែនគីឡូតែព្រះនៅតែស្រង់ខ្ញុំរួចអោយខ្ញុំអាចមាន
គ្រួសារមួយមានមនុស្សម្នាក់ដែលស្រលាញ់ខ្ញុំដែលខ្វាល់ខ្វាយពីខ្ញុំដែលខ្ញុំអត់មានអីហូបគេអោយខ្ញុំហូបដែលខ្ញុំ អត់មានអីស្លៀកពាក់គេអោយខ្ញុំស្លៀកពាក់គ្រប់គ្រាន់ច្រើនមែនទែន។
សូម្បីតែខោអាវរាល់ថ្ងៃខ្ញុំស្លៀកមិនអស់ផង
ដែលពីមុខខ្ញុំអត់អីស្លៀកឥឡូវខោអាវខ្ញុំកាត់ច្រើនណាស់ទាំងបាវៗទុកទាំងស្បោងទុកខោអាវខ្ញុំស្លៀកមិនអស់ទេខ្ញុំតែងតែមានអំរគុណសម្រាប់ខ្ញុំគ្មានអីស្លៀកតែព្រះបានផ្តល់អោយខ្ញុំមានស្លៀកពាក់ដែលខ្ញុំក្រអត់អីញ៉ាំមិនដែលស្គាល់ឆ្ងាញ់ទេឥឡូវអាចមានអីញ៉ាំអញ្ចឹងបើសិនជាអត់មានព្រះទេគឺខ្ញុំអត់មានថ្ងៃហ្នឹងសោះ។

ក៖ បាទ! បង។

ខ៖ ក្រុមគ្រួសារខ្ញុំធ្លាក់ទៅក្នុងនរកដ៏សែនជ្រៅតែព្រះនៅព្យាយាមស្រង់ពួកយើងម្តងមួយៗហ្នឹងហើយសូម្បីអត់
លុយរៀនក៏ព្រះជួយនាំមនុស្សផ្សេងៗដើម្បីផ្តល់លុយអោយពួកយើងរៀនអញ្ចឹងកើតឡើងដោយសារព្រះទាំង
អស់ហើយយើងនៅតែចាំពរជ័យជាច្រើនទៀតដោយសារការបម្រើនៅក្នុងព្រះវិហារការជឿស្មោះពីចិត្តទោះជា
ឧបសគ្គប៉ុន្មានក៏យើងនៅតែទៅព្រះវិហារព្រោះត្បិតយើងមិនល្អឥតខ្ចោះសាតាំងវាចូលមកល្បួងយើងខ្លាំងជឿព្រះប៉ុន្មានសាតាំងចូលមកប៉ុណ្ណឹងអញ្ចឹងធ្វើអោយយើងល្អឥតខ្ចោះយើងមានអំពើបាបជឿប៉ុន្មានល្បួងប៉ុណ្ណឹង។ ចា៎!

ប៉ុន្តែនៅតែបែកចែកផ្សេងថាធ្លាក់ទៅក្នុងការល្បែងណាមួយតែខ្ញុំបែងចែកដាច់ថាព្រះរបស់អញ្ចឹងធ្វើអោយខ្ញុំ បន្តដំណើរដើរទៅមុខទៀត។

ក៖ ហ្នឹងហើយ។ ហើយសូមសួរមួយទៀតសម្រាប់បងឥឡូវបងមានកូននៅ?

ខ៖ អ៎!ខ្ញុំមានកូនជាមួយប្ដីមុខ។ កូនមួយអាយុប្រាំឆ្នាំហើយហ្នឹងគ្រួសារមុនណាស់។

ក៖ បាទ! បង។

ខ៖
ហើយអ្នកគ្រួសារក្រោយគេនៅកម្លោះទេហើយគេមកស្រលាញ់ខ្ញុំដោយខ្ញុំមានកូនហើយគេអត់ប្រកាន់នេះ គឺជាពរជ័យមួយផ្សេងទៀតសម្រាប់ខ្ញុំ។
ខ្ញុំសប្បាយចិត្តខ្លាំងដែលគេអោនលន់ទូមករកយើងដែលយើងក្រហើយ យើងមេម៉ាយទៀត។

ក៖ ហ្នឹងហើយបង។

ខ៖ ហើយគេលូនមករកហើយនេះជាថាអ្វីទាំងអស់គឺមកពីព្រះទាំងអស់។

ក៖ បាទ! បងហ្នឹងហើយបង។

ខ៖ ចាំ!

ក៖ អញ្ចឹងកូនបងឈ្មោះអីដែរបង?

ខ៖ ឈ្មោះព្រុំវាលៀមចនថៀលលើហៅតុងៗ។

ក៖ អាយុប៉ុន្មានហើយបង?

ខ៖
អាយុប្រាំឆ្នាំតែនៅពេលទៅដល់អាមេរិចនោះគឺហៅគាត់ឈ្មោះចនដោយសារគេមិនអាចហៅឈ្មោះខ្មែរទេគេ
ហៅតាមឈ្មោះនៅក្នុងហ្នឹងនៅក្នុងបញ្ជីហ្នឹងចុះខ្ញុំតែងតែហៅចនពីនេះអោយហើយ។

កៈ ហ្នឹងហើយបង។

ខៈ ចាំ!

កៈ កូនស្រីរឺកូនប្រុសបង?

ខៈ កូនប្រុស។

កៈ កូនប្រុសណោះ។

ខៈ ចាំ!

កៈ ហើយគាត់ធ្វើអីគេវិញបង?

ខៈកូនហ្នឹងរៀនអង់គ្លេសមត្តេយ្យពីរឆ្នាំហើយប៉ុន្មានខែហ្នឹងអត់អោយទៅរៀនដោយសារខ្ញុំស្រាវជ្រាវទៅកូនខ្ញុំអត់ចេះអីទេគ្រាន់តែយកកូនអោយទៅធ្វើរគេអញ្ចឹងណាស់អញ្ចឹងកូនខ្ញុំអត់ចេះអីសោះខ្ញុំបានធ្វើតេសកូនខ្ញុំណាមួយខ្ញុំធ្លាប់ធ្វើគ្រូទៀតអញ្ចឹងខ្ញុំដឹងថាកូនខ្ញុំវាយ៉ាងម៉េចអញ្ចឹងខ្ញុំអោយផ្អាករៀនសិនខ្ញុំបង្រៀនខ្លួនឯងនៅផ្ទះដោយសារតែខ្ញុំធ្លាប់ធ្វើគ្រូនៅអង្គការ។

កៈ បាទ!

ខៈ ឥឡូវកូនខ្ញុំចេះច្រើនបន្ទាប់ពីខ្ញុំបង្រៀនបានមួយខែហ្នឹងណាស់។
កូនខ្ញុំចេះច្រើនហើយហ្នឹងហើយ។

កៈ បាទ!
បងអរគុណច្រើនហើយអញ្ចឹងឥឡូវខ្ញុំចង់សូមសួរបន្ថែមទៀតអំពីជីវប្រវត្តិរបស់បងអញ្ចឹងណាស់តាំងពី កូនរហូតដល់ធំមកបងមានភាពលំបាកណាមួយនៅក្នុងឆាកជីវិតអត់បង?
បងមានចងចាំទាំងអស់ហ្នឹងទេ?

ខៈ
ខ្ញុំលំបាកជាងគេនោះខ្ញុំគ្រួសារធ្វើបាបហ្នឹងឯងដែលគេចិត្តអត់បានហ្នឹងគ្រួសារមុនណាស់។

កៈ បាទ!

ខ៖
ដែលគេចិត្តអត់បានដល់អញ្ចឹងទៅខ្ញុំចងចាំអត់ភ្លេចហើយខ្ញុំព្យាយាមបំភ្លេចដែលតែមិនភ្លេច ដោយសារខ្ញុំចិត្ត ល្អ
ខ្ញុំសប្បុរសណាស់ខ្ញុំមិនចេះមើលងាយគេទេប៉ុន្តែពេលដែលខ្ញុំជួបមកវិញវាបញ្ច្រាស់ពីខ្ញុំ។ ខ្ញុំជួបអ្នកចិត្តមិន
បានចិត្តមិនសប្បុរសចំពោះខ្ញុំធ្វើអោយខ្ញុំតូចចិត្តខ្លាំងហើយធ្វើអោយខ្ញុំជឿចាប់ខ្លាំងហើយដែលខ្ញុំមិនអាចបំភ្លេច បានដល់ពេលនិយាយរឿងហ្នឹងធ្វើអោយខ្ញុំឈឺចាប់ខ្លាំង។

ក៖ បាទ! បងហ្នឹងហើយ។

ខ៖ ចាំ! ដែលខ្ញុំមិនអាចបំភ្លេចបានហ្នឹងលំបាកបំផុតដែលខ្ញុំពោះធំខ្ញុំត្រូវការប្តី
ប្តីអត់មើលខ្ញុំឃ្លានខ្ញុំចាញ់កូនខ្ញុំ
ត្រូវការគេអត់ខ្វាល់ខ្ញុំអត់អីស្លៀកគេអត់ខ្វាល់ខ្ញុំកើតកូនអត់មានប្តីហ្នឹងជាអ្វីដែលខ្ញុំលំបាកជាងគេបំផុត។

ក៖ បាទ!

ខ៖
ឆ្លងទន្លេហើយត្រូវការប្តីមើលថៃគេអត់ខ្វាល់អញ្ចឹងធ្វើអោយខ្ញុំឧបសគ្គនេះខ្ញុំមិនអាចបំភ្លេចបានខ្ញុំឈឺចាប់ជាង គេកន្លែងហ្នឹង។

ក៖ បាទ! បងហ្នឹងហើយ។
ហើយបងមានភាពឈឺចាប់អីផ្សេងពីហ្នឹងទៀតទេថាជីវភាពរស់នៅមានអីផ្សេងៗ ទៀតទេ?

ខ៖
ឈឺចាប់ជាងគេគឺក្រុមគ្រួសារខ្ញុំដែលខ្វះខាតដែលខ្ញុំជួយមិនទាន់បានច្រើនខ្ញុំគ្រាន់ជួយបានធ្វើផ្ទះខ្លះ។

ក៖ ហ្នឹងហើយបង។

ខ៖ ដែលផុតពីទឹកអត់ទាន់បានជួយអោយវាធូរជាងហ្នឹងនៅ។
អញ្ចឹងខ្ញុំនៅពិបាកចិត្តត្រង់ថាធ្វើម៉េចជួយប្អូនថែម
ទៀតតែខ្ញុំមិនហ៊ានប៉ះពាល់លុយក្រុមគ្រួសារប្ដីខ្ញុំទេ។
ខ្ញុំមិនហ៊ានខ្លាចគេស្អំខ្លាចគេអន់ចិត្តខ្ញុំខ្លាចជាងគេខ្លាចគេ អន់ចិត្ត។

ក៖ បាទ!បង។

ខ៖ ជាមូលហេតុហ្នឹងខ្ញុំអត់ហ៊ានសួររឿងលុយកាក់រឿងប្ដីខ្ញុំ ខ្ញុំអត់ប៉ះពាល់លុយគេទេ។

ក៖ បាទ!បងហ្នឹងហើយបង។
អញ្ចឹងអរគុណច្រើនសម្រាប់បងផ្ដល់បទពិសោធភាពជូរចត់អ្វីដែលបងមាននៅក្នុង
ឆាកជីវិតអញ្ចឹងណាស់។

ខ៖ ចាំ!

ក៖ អញ្ចឹងសម្រាប់ភាពល្អអ្វីដែលជាការល្អនៅក្នុងឆាកជីវិតរបស់បង?

ខ៖ ដែលជួបបច្ចុប្បន្នហ្នឹងណោះ។

ក៖ តាំងពីតូចរហូតដល់ធំឥឡូវអីហ្នឹងណាស់អ្វីដែលល្អជាងគេបំផុតដែលបងគិតថា...

ខ៖
ល្អជាងគេបំផុតគឺខ្ញុំបានស្គាល់ដំណឹងល្អនេះពិតប្រាកដដែលខ្ញុំមានព្រះវិញ្ញាណបរិសុទ្ធមកស
ន្និតថាព្រះវិហារ នេះពិត។
អញ្ចឹងនៅពេលដែលខ្ញុំកាន់ព្រះគម្ពីរមរមនលើកទីមួយខ្ញុំអធិស្ឋានច្រើនដងខ្ញុំកាន់ព្រះគម្ពីរមរម
នហើយខ្ញុំមានព្រះ វិញ្ញាណចូលប្រហែលខ្ទង់២០ដង៣០ដង។
ព្រះវិញ្ញាណមកបញ្ជាក់ថាព្រះវិហារនេះគម្ពីរនេះពិត។

ក៖ អ៎! បាទ! បង។

ខ៖
ហើយរឿងដែលខ្ញុំសប្បាយជាងគេហើយសប្បាយលើកទីពីរខ្ញុំបានទៅបេសកម្មហើយសប្បាយជាងគេលើទីបី ខ្ញុំជួបគ្រួសារក្រោយនេះគេស្រឡាញ់យើងខ្លាំងគេអោនគេលូនមករកយើង។

ក៖ ហ្នឹងហើយបង។

ខ៖
ហ្នឹងហើយគេយល់ចិត្តយើងគេស្តាប់យើងគ្រប់ពាក្យទាំងអស់សប្បាយចិត្តជាងគេខ្ញុំទាំងពីរនាក់អត់ដែលទាស់ គ្នាសោះ។

ក៖ បាទ!

ខ៖
ដោយសារខ្ញុំប្រយ័ត្នប្រយែងលុយកាក់របស់គេខ្ញុំអត់ប៉ះពាល់គេធ្វើអីខ្ញុំអោយសេរីភាពទៅគេទាំងអស់។

ក៖ ហ្នឹងហើយ។

ខ៖
គេចង់បានអីគឺពាក្យសម្តីរបស់គេគឺខ្ញុំស្តាប់ទាំងអស់ខ្ញុំសប្បាយចិត្តកន្លែងហ្នឹងខ្លាំងគឺខ្ញុំអត់ដែលឈ្លោះគ្នាហ្នឹង
ណាស់ខ្ញុំសប្បាយចិត្តខ្លាំងណាស់ហើយខ្ញុំអត់ចង់បានអីពីគេទេអោយតែមានបាយហូបជុំគ្នាគឺអស់ចិត្តហើយទោះបីមានក្រក៏ខ្ញុំអត់ខ្វាល់ទេព្រោះខ្ញុំលំបាកឆ្អែតហើយរហូតដល់ចំណាស់នេះហើយខ្ញុំសូមអោយតែមានអ្នកស្រឡាញ់
នៅក្បែរខ្ញុំមើលថៃខ្ញុំញុំាបាយញុំាជាមួយគ្នានេះជាអ្វីដែលខ្ញុំចង់បានរីឯទ្រព្យសម្បត្តិខ្ញុំមិនអើពើ។ចាំ!

ក៖
អរគុណច្រើនបងហើយបងមានអ្វីបន្ថែមពីហ្នឹងទៀតទេពីអ្វីដែលបងគិតថាចង់បន្ថែមទៀតរឺគិតថាមានតែ ប៉ុណ្ណឹងឯង។

ខ៖
ខ្ញុំចង់បន្ថែមថាខ្ញុំមានអំរគុណសម្រាប់ដំណឹងល្អនេះហ្នឹងការចែកចាយបទពិសោធនេះទៅដល់កូនចៅជំនាន់ ក្រោយដែលអាចដឹងពីជីវិតប្រវត្តិ។
ខ្ញុំបន្តទៀតហើយកូនខ្ញុំចៅខ្ញុំចែកមើលប្រវត្តិនេះហ្នឹងស្ដាប់ឈើខ្ញុំដែលបាន
ថ្លែងនៅថ្ងៃនេះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៦។
អញ្ចឹងខ្ញុំបានថ្លៃថ្ងៃនេះទៅកាន់កូនចៅខ្ញុំជំនាន់ក្រោយដែលបានស្ដាប់លឺខ្ញុំហើយអនុវត្តទៅតាមអ្វីដែលខ្ញុំបានចែកចាយនេះក៏ដូចជាចេះយល់ចិត្តក្រុមគ្រួសារយើងចេះស្ដាប់កុំអោយមានទំនាស់ទាស់ទែងរឿងលុយកាក់ត្រូវចេះ ខ្លាចចិត្តគ្នាទើបអត់ឈ្លោះគ្នា។

ក៖ បាទ! បង។

ខ៖ បាទ!។

ក៖ បាទ!
អរគុណច្រើនបងសម្រាប់ការផ្ដល់សម្ភាសសម្រាប់ថ្ងៃនេះហើយពីមុបញ្ចប់ខ្ញុំសូមថតរូបបងមួយដែលដើម្បីដាក់នៅក្នុងវេបសាយរបស់ពួកយើងអញ្ចឹងណាស់ដាក់ទាំងសំលេងដាក់ទាំងរូបថតដើម្បីអោយកូនចៅរបស់បងបានឃើញភាពរីករាយពេលដែលសម្ភាសហ្នឹងរូបរាងយ៉ាងម៉េចអញ្ចឹងណាស់ដើម្បីអនុស្សាវរីយ៍អញ្ចឹងណាស់បង។

ខ៖ ចាំ!

ក៖
ហើយអញ្ចឹងអត់អីបើសិនជាងពេលពួកយើងដាក់ការសម្ភាសបងនិងរូបថតបងនៅក្នុងវេបសាយនៅក្នុង សាលារៀនយើងអត់អីទេណោះ។

ខ៖ ចាំ! អត់អីទេដោយសារទុកជាឯកសារសម្រាប់អ្នកជំនាន់ក្រោយ។

ក៖ បាទ!
បងហ្នឹងហើយអញ្ចឹងសូមថ្លៃអំរគុណខ្លាំងមែនទែនសម្រាប់ឱកាសនេះដែលបងផ្ដល់អោយខ្ញុំធ្វើការ សម្ភាសបង។